CITY OF LONG BEACH — PRESS RELEASE

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ៣០ ខែឧសភាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចផ្តល់នូវខែលការពារមុខចំនួន ១០០០ ដោយឥតគិតថ្លៃដល់ភោជនីយដ្ឋានឡុងប៊ិច

ទីក្រុងឡុងប៊ិច, រដ្ឋកាលីហ្វ័រញ៉ា - ថ្ងៃនេះទីក្រុងឡុងប៊ិចប្រកាសពីកម្មវិធីឥតគិតថ្លៃដែលផ្តត់ផ្គង់ខែលការពារមុខដល់ទៅ ១០០០ ខែលដល់ភោជនីយដ្ឋានដែលមានមូលដ្ឋានៅឡុងប៊ិច។ បទបញ្ជាសុខភាពដែលបានចូលជាធរមានកាលពីយប់មិញថ្ងៃទី ២៩ ខែឧសភាតម្រូវឱ្យអ្នករត់តុនៅភោជនីយដ្ឋានពាក់ទាំងម៉ាស់និងខែលការពារមុខដើម្បីបង្កើនការការពារដល់បុគ្គលិកនិងអតិថិជន។ ដោយទទួលស្គាល់ថាខាងភោជនីយដ្ឋានប្រហែលជាមិនមានភាពងាយស្រួលក្នុងការរកខែលការពារឱ្យទាន់ចុងសប្តាហ៍នេះទីក្រុងបានបង្កើតកម្មវិធីឥតគិតថ្លៃនេះយ៉ាងឆាប់រហ័ស។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "យើងចង់ផ្តល់នូវការការពារដល់ភោជនីយដ្ឋាននិងកម្មកររបស់យើង។ យើងនឹងបន្តអនុវត្តកម្មវិធីផ្សេងៗដើម្បីជួយដល់អាជីវកម្មខ្នាតតូចរបស់យើង។"

ដោយព្រោះអតិថិជននៅពេលបរិភោគអាហារនៅភោជនីយដ្ឋាននឹងមិនពាក់របាំងមុខនោះហានិភ័យនៃការឆ្លងទៅវិញទៅមកពីអ្នករត់តុគឺខ្ពស់ហើយការពាក់ទាំងក្រណាត់គ្របមុខព្រមជាមួយនិងខែលការពារមុខនឹងផ្តល់នូវការការពារបន្ថែម។

ខែលការពារមុខក៏ជាតម្រូវការមួយនៅក្នុងបទបញ្ញាសុខភាពនៃខោនធី Los Angeles និងមានភាពតឹងរ៉ឹងជាងតំបន់ជុំវិញផ្សេងទៀតដោយសារតែចំនួនករណី COVID-19 ខ្ពស់នៅក្នុងខោនធី Los Angeles។ ឡុងប៊ិចបានអនុមត័នូវតម្រូវការដូចគ្នានឹងខោនធី Los Angeles ដោយព្រោះការដែលរដ្ឋបានអនុញ្ញាតឱ្យឆ្ពោះទៅមុខក្នុងការបើកភោជនីយដ្ឋានឡើងវិញត្រូវផ្អែកលើការព្រមព្រៀងទូទាំងខោនធីសម្រាប់យុត្តាធិការសុខភាព។

អ្នកតំណាងឱ្យភោជនីយដ្ឋាននីមួយៗអាចមកយកខែលបាង់មុខនៅចំណតនៃទីស្នាក់ការមន្ទីពន្លត់អគ្គីភ័យរបស់ទីក្រុងឡុងប៊ិចដែលមានទីតាំងនៅ 3205 Lakewood Boulevard។ ខែលត្រូវបានកំណត់ត្រឹមតែប្រាំខែលក្នុងមួយទីតាំងតែប៉ុណ្ណោះហើយអាទិភាពនឹងផ្តល់ជូនអ្នកដែលមកដល់មុន។

អ្នកតំណាងឱ្យភោជនីយដ្ឋានអាចមកយកខែលបាននៅថ្ងៃនេះថ្ងៃសៅរ៍ទី ៣០ ខែឧសភាចាប់ពីម៉ោង ១ រសៀលដល់ម៉ោង ៤ រសៀលហើយនៅថ្ងៃស្អែកថ្ងៃអាទិត្យទី ៣១ ខែឧសភាចាប់ពីម៉ោង ១០ ព្រឹកដល់ម៉ោង ១ រសៀល។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្តដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើប្រពន្ធ័សង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

\# # #